ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២០ លេខ៧៧ ត្រីមាសទី០៤ ឆ្នាំ២០២០

រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

៣០-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/១០៥៥ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ឯម ច័ន្ទមករា** ជារដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្ថែមលើមុខងារបច្ចុប្បន្ន ៩៤៣៩

៣០-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/១០៥៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា និងជាជំនួយការរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ២ រូប ៩៤៤០

៣០-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/១០៥៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ដល់លោក **ស៊ា សឿស៊ាន** **(HSIEH CHIH-HSIEN)** ជនជាតិចិន សញ្ជាតិចិន(តៃវ៉ាន់) ៩៤៤១

៣០-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/១០៥៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **សេន ស៊ីអ៊ី** **(SHEN SHIYI)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **អេដែន វ៉ាង** **(EDEN WANG)** ៩៤៤២

៣០-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/១០៦០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ត្រាន់ ឌូ** **(TRAN DU)** ជនជាតិវៀតណាម សញ្ជាតិកាណាដា ៩៤៤៣

៣០-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/១០៦១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លាង ជាជុន** **(LIANG JIAJUN)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **យូរី បែនហ្វដ** **(YURIY BENFORD)** ៩៤៤៤

៣០-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/១០៦២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី កញ្ញា និង ព្រះសង្ឃ ចំនួន ៥៥ រូប/អង្គ ៩៤៤៥

៣០-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/១០៦៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក លោកស្រី និងព្រះសង្ឃ ចំនួន ៥៤ រូប/អង្គ ៩៤៤៧

១-១០-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៦៤ ស្តីពី ការតម្លើង ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់ឧត្តមសេនីយ៍ទោ **ម៉ុក ឆវណ្ណា** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៩៤៤៩

១-១០-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៦៥ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ឯក ឆេងហួត** ពីទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៦ មានឋានៈស្មើ រដ្ឋលេខាធិការ ៩៤៥០

១-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៦៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ប៉ាយ ហោរអ៊ី** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៦ មានឋានៈស្មើ រដ្ឋមន្ត្រី ដោយពុំទទួលប្រាក់បំណាច់មុខងារ	៩៤៥១
៨-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៦៧ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ចាន់ ផូ** ជាទីប្រឹក្សាសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នីតិកាលទី៤ មានឋានៈស្មើ រដ្ឋលេខាធិការ	៩៤៥២
៩-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៦៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **វៃ ស៊ីយូ** **(WEI SIYU)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ហ៊ុន សំណាង** **(HUN SAMNANG)**	៩៤៥៣
៩-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៧០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់កញ្ញា **ស៊ូ ទីងអ៊ី** **(HSU TING YU)** ជនជាតិចិន សញ្ជាតិចិន(តៃវ៉ាន់)	៩៤៥៤
១០-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៧១ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម ឧត្តមសេនីយ៍ឯក **តាត និមល** ពីអនុប្រធានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក	៩៤៥៥
១០-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៧២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ ចំនួន ៨ រូប និងតែងតាំងមុខតំណែង នាយទាហាន ចំនួន ៦ រូប នៃ កងយោធពល ខេមរភូមិន្ទ	៩៤៥៦
១០-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៧៣ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	៩៤៥៨
១០-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៧៤ ស្តីពី ការផ្តល់នីតិសម្បទាឡើងវិញឱ្យឈ្មោះ **ស៊ុន សុត្រ័ក្រ** ភេទ ប្រុស កើតថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ១៩៨៣ ដែលត្រូវបានហាមឃាត់មិនឱ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ តាមអំណាចសាលដីកាលេខៈ ៣៤០(ឆ)	៩៤៦៣
១០-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៧៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **សៃ ឡូត** **(SAI LOOT)** ជនជាតិមីយ៉ាន់ម៉ា សញ្ជាតិមីយ៉ាន់ម៉ា	៩៤៦៤
១០-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៧៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **សៃ ខាម** **(SAI KHAM)** ជនជាតិមីយ៉ាន់ម៉ា សញ្ជាតិមីយ៉ាន់ម៉ា	៩៤៦៥
១០-១០-២០២០	-ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៧៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ង៉ៀ វ៉ី** (**XIA, WEI**) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ង៉ៀ យីហាក** (**XIA, YIHAG**)	៩៤៦៦

១០-១០-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៧៨ ស្តីពី ការផ្តល់សញ្ញាតិខ្មែរ ដោយសញ្ញាតូបនីយកម្ម ដល់លោក **ឈិន ប៊ូ (CHEN, BO)** ជនជាតិចិន សញ្ញាតិចិន ដោយប្តូរឈ្មោះជា **ឈិន ហោឡុង (CHEN, HAO LONG)** ៩៤៦៧

១៧-១០-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១០២០/១០៧៩ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **គុង ចំរើន** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយមិនទទួលប្រាក់បំណាច់មុខងារ ៩៤៦៨

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

៣០-៩-២០២០ -អនុក្រឹត្យលេខ ១៦១ អនក្រ.បក ស្តីពី បែបបទ និងនីតិវិធីនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យ ៩៤៦៩

២-១០-២០២០ -អនុក្រឹត្យលេខ ១៦២ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៩៤៧៣

៥-១០-២០២០ -អនុក្រឹត្យលេខ ១៦៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៤៧៦

៧-១០-២០២០ -អនុក្រឹត្យលេខ ១៦៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៤៧៨

៨-៩-២០២០ -អនុក្រឹត្យលេខ ៧៩៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៩៤៨០

៨-៩-២០២០ -អនុក្រឹត្យលេខ ៧៩៦ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៩៤៨២

៨-៩-២០២០ -អនុក្រឹត្យលេខ ៧៩៧ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៩៤៨៣

៨-៩-២០២០ -អនុក្រឹត្យលេខ ៧៩៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៤៨៤

៩-៩-២០២០ -អនុក្រឹត្យលេខ ៧៩៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៤៨៥

៩-៩-២០២០ -អនុក្រឹត្យលេខ ៨០០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩៤៨៦

៩-៩-២០២០ -អនុក្រឹត្យលេខ ៨០២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩៤៨៧

៩-៩-២០២០ -អនុក្រឹត្យលេខ ៨០៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៤៨៨

៩-៩-២០២០ -អនុក្រឹត្យលេខ ៨០៤ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៩៤៩០

១០-៩-២០២០ -អនុក្រឹត្យលេខ ៨០៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៤៩២

១០-៩-២០២០ -អនុក្រឹត្យលេខ ៨០៦ អនក្រ.តត ស្តីពី ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៩៤៩៤

១០-៩-២០២០ -អនុក្រឹត្យលេខ ៨០៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩៤៩៥

១០-៩-២០២០ -អនុក្រឹត្យលេខ ៨០៨ អនក្រ.តត ស្តីពី ការបញ្ចប់តួនាទី មន្ត្រីតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអមស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ៩៤៩៧

១១-៩-២០២០ -អនុក្រឹត្យលេខ ៨០៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៩៤៩៩

១១-៩-២០២០ -អនុក្រឹត្យលេខ ៨១០ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៩៥០៣

២~សេចក្ដីសម្រេច

២១-១០-២០២០ -សេចក្ដីសម្រេច ៩៨ សសរ ស្ដីពី ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីកំណត់តំបន់រមណីយដ្ឋានប្រាសាទបន្ទាយឆ្មាឡើងវិញ ៩៥៤៤

III~ការងារបណ្ដាក្រសួង

១~ធនាគារជាតិ នៃ កម្ពុជា

២៦-៦-២០១៩ -ប្រកាសលេខ ធ១៤-០២០-៣៥០ ប្រក ស្ដីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង ៩៥៤៧

២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣១-១២-២០១៩ -ប្រកាសលេខ ១៤៧៦ សហវ.អថ ស្ដីពី ការប្រគល់កាតព្វកិច្ចប្រមូលចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ (*តទៅ រាជកិច្ចលេខ៧៨*) ៩៥៥០

៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

៦-៤-២០២០ -ប្រកាសលេខ ២០៧៧ ប្រក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម ៩៥៦១

៦-៤-២០២០ -ប្រកាសលេខ ២០៧៨ ប្រក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល ៩៥៦២

ព្រះរាជក្រឹត្យ

នស/រកត/០៩២០/ ១០៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងមុខតំណែងឯកឧត្តម **ឯម ច័ន្ទមករា** ជារដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

នរោត្តម សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៩២០/ ១០៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងនិងផ្តល់ឋានៈជាទីប្រឹក្សា និងជាជំនួយការរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ០២រូប ៖

១. ឯកឧត្តម **អេង រ៉ា** ជាទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២. ឯកឧត្តម **អ៊ូក សុផុន** ជាជំនួយការ មានឋានៈស្មើ អគ្គនាយក។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២០

នរោត្តម សីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៩២០/១០៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **ស៊ា ស៊ើស៊ាន** (HSIEH CHIH-HSIEN) ជនជាតិ ចិន សញ្ជាតិ ចិន (តៃវ៉ាន់) កើតនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៣ ក្រុងតៃប៉ិ សាធារណរដ្ឋចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣០.កញ.២០២០.១០៥០

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានយកសេចក្តីថ្វាយ
ឧបនាយករដ្ឋមន្ត្រី ប្រធានការិយាល័យគណៈរដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៩២០/ ១០៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **សេន ស៊ឺអ៊ី** (SHEN SHIYI) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៨៨ នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **អេដែន វ៉ាង** (EDEN WANG)។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ចបស.២០០៩.១០៥៦

ន សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ ... បានថ្លឹងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៩២០/ ១០៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់អ្នកស្រី **ត្រាន់ ឌូ** (TRAN DU) ជនជាតិ វៀតណាម សញ្ជាតិ កាណាដា កើតនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៣ នៅទីក្រុងសៃហ្គន ប្រទេសវៀតណាម។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៧៧.២០០៩.១០៥២

ន សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៩២០/ ១០៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **លាង ជាជុន** (LIANG JIAJUN) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៨២ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **យូរី បែនហ្វដ** (YURIY BENFORD)។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

០៣.២០០៩.១០៥៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២០

នសីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៩២០/ ១០៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស **ជាតូបការ** :

១- ឯកឧត្តម **ស៊ាក ឡេង** ២- លោក **ថាច់ សុធា**
៣- លោក **សៃ សុឃន** ៤- លោក **ណុប ឧត្តា**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ព្រះគ្រូវិចិត្តមេធា **សាន រស់** ២- ព្រះតេជគុណ **តុន ម៉ៅ**
៣- ឯកឧត្តម **គិន ឆេងលី** ៤- លោក **កែម វាសនា**
៥- លោក **ឡាយ សាម៉ុន** ៦- លោក **ជា គឹមសួរ**
៧- លោក **ឈុន ម៉ៅ** ៨- លោក **ម៉ៃ ម៉ារ៉ាត់**
៩- លោក **នៅ វុទ្ធា** ១០- លោក **វ៉ែន ឧត្តា**
១១- លោក **ប៊ុត ផៃ** ១២- លោក **ឡេក ហឿន**
១៣- លោក **ធូក ចាន់ឌី** ១៤- បណ្ឌិត **ឌី ពុទ្ធារ៉ា**
១៥- លោក **សៀន យូឡេង** ១៦- លោក **យ៉ុំ ម៉េងហុង**
១៧- លោក **សៀ តុង** ១៨- លោក **សៀ គិរីរាជ**
១៩- លោក **អេ គិមអាន** ២០- ឯកឧត្តម **មុយ បញ្ញារិទ្ធ**
២១- លោក **ផល ពិសិទ្ធ** ២២- លោក **ប៉ាង សូវៀត**

គ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះសីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម **មាន សំអុល** ២- ឯកឧត្តម **ធីង គឹមម៉េង**
៣- ឯកឧត្តម **មួន វាសនា** ៤- លោកជំទាវ **អុក សាវី**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

៥- លោកជំទាវ **អ៊ី សុភ័ក្រ្ត**
៦- លោកជំទាវ **ស៊ឹង សុគន្ធារី**
៧- លោក **អ៊ុន ពៅសម្បត្តិ**
៨- លោក **ហេង ពិសិដ្ឋ**
៩- លោក **ប៊ុន សួរ**
១០- លោកស្រី **ទាវ សុនិភា**
១១- លោក **លី សុភាលីន**
១២- លោកស្រី **ហេង ណារ៉ាឡែន**
១៣- លោកស្រី **មាឃ នីតា**
១៤- លោក **អ៊ុម មករា**
១៥- លោក **ហេង ឡុង**
១៦- កញ្ញា **ហុក ទិព្វគីមឡាយ**
១៧- លោក **កែវ រ័ត្នមុនី**
១៨- លោក **កៅ សុវណ្ណសុផល**
១៩- លោក **សោម វីរៈ**
២០- លោក **សុខ មករា**
២១- លោក **ឃន ឆន**
២២- លោក **ឌ៉ាន់ សុខន**
២៣- លោក **រឿន ភារិទ្ធ**
២៤- លោក **យ៉ន ជេដ្ឋា**

ឃ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សប្ញទ្ធិ** :

១- លោក **ឡៀប ឡឿង**
២- លោក **មុំ ខន្ធរ៉ុនា**
៣- លោក **ចាន់ សារ៉េល**
៤- លោក **សឹង សុឃាង**
៥- លោក **ហេង ហាក់**

នស.រកត.០៩២០.១០៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានចម្លងចេញពីច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៩២០/ ១០២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស **ជាគូបការ** :

១- ឯកឧត្តម **ឆោម ហាក់** ២- លោក **កែវ ហុង**
៣- លោក **ឱម ស៊ីន**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោក **អេង កុសល** ២- លោក **សល់ សំអេង**
៣- លោក **ជួង ស៊ីណែត** ៤- លោក **អ៊ុយ សុធារ័ត្ន**
៥- លោក **ហោ លាងសេង** ៦- លោក **ផង់ ប៉េងថេង**
៧- លោក **ហេង កុសល** ៨- លោក **ទ៉េង មិថុនា**
៩- លោក **ធីម ថៃ** ១០- លោក **នី ម៉ូណោ**
១១- លោក **ឡុង សុខា** ១២- លោក **ចៅ សុខា**
១៣- លោក **អ៊ឹង ម៉េងស្រៀង** ១៤- លោក **ឈួន ពិសិដ្ឋ**
១៥- លោក **ពៅ ចាន់ឌី** ១៦- លោក **សំ កុសល**
១៧- លោក **ឯម បូនិត** ១៨- លោក **លី ខេមរា**
១៩- លោក **អេន រក្សា** ២០- លោកស្រី **សំ សុខន**
២១- លោក **សឹង ចាតទិដ្ឋា** ២២- លោក **ប៊ុន រស្មី**

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ព្រះតេជគុណ **ស៊ុម សុធារិទ្ធ** ២- លោក **ខេង ជិន**
៣- លោក **កែវ យឿម** ៤- លោក **ស៊ា សុភ័ក្រ**
៥- លោក **សោម អ៊ែមហេង** ៦- លោក **ម៉េន មាស**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៧- លោក **ព្រហ្ម ម៉ារ៉ា**
៨- លោក **សៀក សីហាន**
៩- លោក **ហុក ធិព្វរុក្ខា**
១០- លោក **គឹម សុធា**

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- ឯកឧត្តម **ពាត សុខុម**
២- លោក **អ៊ី ស៊ុនហេង**
៣- លោក **ខន ជំនោ**
៤- លោក **រិទ្ធ អារុណ្ណាធី**
៥- លោក **ពូ សុវណ្ណា**
៦- លោក **សៅ ស៊ឹម**
៧- លោក **អ៊ុក សាឃួន**
៨- វេជ្ជបណ្ឌិត **គាន សុបុណ្ណា**
៩- លោក **ចាន់ ម៉ាកសែល**
១០- លោក **ស្រី សមវិចិត្រ**
១១- លោក **តាន់ សុខ**
១២- លោក **ថៃ ហ៊ី**
១៣- លោកស្រី **ព្រុំ សុខន**
១៤- លោកស្រី **ជា សំអន**
១៥- លោកស្រី **ជា ស៊ីថា**
១៦- លោក **សេង សុន**
១៧- លោក **ហេង គុយហ៊ាត់**
១៨- លោក **ណុប សុផាណ្ណា**
១៩- លោក **សំ សេរីរតនា**

៣៧.២០០៩.១០៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២០

នរោត្តម សីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២០/ ១០៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ដល់ឧត្តមសេនីយ៍ទោ **ម៉ុក វណ្ណា** អត្តលេខ ០៤៧៧៧ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

ចាវសរ.២០១០.១០៤៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២០/១០៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដាឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៦ នាថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ត្រូវនឹងថ្ងៃទី៦ ខែ កញ្ញា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ:នស/រកត/០៩១៨/៩៤៤ ចុះថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បញ្ចប់មុខតំណែងឯកឧត្តម **ឯក ឆេងហួត** ពីទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៦ មានឋានៈស្មើរដ្ឋលេខាធិការ តាមលេខរៀងទី១០ មាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៥៥ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨។

មាត្រា២ : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ចារស.២០១០.១០៤៧

នសីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២០/១០៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដាឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៦ នាថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ត្រូវនឹងថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ប៉ាយ ហោរអ៊ី** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៦ មានឋានៈស្មើ **រដ្ឋមន្ត្រី** ដោយពុំទទួលប្រាក់បំណាច់មុខងារ។

មាត្រា២ : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/ ១០២០ / ១០៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផល នៃសម័យប្រជុំលើកដំបូងព្រឹទ្ធសភា នីតិកាលទី៤ នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ ស្តីពីការជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ចាន់ ផូ** ជាទីប្រឹក្សាសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នីតិកាលទី៤ មានឋានៈស្មើ **រដ្ឋលេខាធិការ**។

មាត្រា២ : សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០២០
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ចរក.២០១០.១០៩៩

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/១០២០/១០២៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **វៃ ស៊ីយូ** (WEI SIYU) ជនជាតិចិន សញ្ជាតិចិន កើតនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៩ នៅខេត្តជាំងស៊ី សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ហ៊ុន សំណាង** (HUN SAMNANG)។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០២០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

បរ.ន.ក.ជ.ព.ល

ការ. ៤០១០.១០៧៦

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

បានយកសេចក្តីគោរពតាមច្បាប់ដើម
ជូននាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/១០២០/១០៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់កញ្ញា **ស៊ូ ធីងអ៊ី** (HSU TING YU) ជនជាតិចិន សញ្ជាតិចិន (តៃវ៉ាន់) កើតនៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៩ នៅខេត្តតៃវ៉ាន់ សាធារណរដ្ឋចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០២០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ករ៧.២០២០.១០៩២

(ហ.ស.)

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២០/១០៥៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហិតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បញ្ចប់មុខតំណែងឯកឧត្តម ឧត្តមសេនីយ៍ឯក **តាត និមល** អត្តលេខ ៧១៩១០ ពីអនុប្រធានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០២០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហ.ត.

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

៧១៩១. ២០១០- ១០៩៧

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២០/ ១០៧២

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៨ រូប ៖

ក-ឋានន្តរស័ក្តិនាយឧត្តមសេនីយ៍

១-ឧត្តមសេនីយ៍ឯក **ហម គិន** អត្តលេខ ០០០០៧០

២-ឧត្តមសេនីយ៍ឯក **មាស ថង** អត្តលេខ ០០០០៩៤

៣-ឧត្តមសេនីយ៍ឯក **តេង ឈួន** អត្តលេខ ០០០៣១៧

៤-ឧត្តមសេនីយ៍ឯក **ជា សារ៉ន** អត្តលេខ ០០០០៩០

៥-ឧត្តមសេនីយ៍ឯក **ម៉ៅ នែន** អត្តលេខ ០០០១១៧

៦-ឧត្តមសេនីយ៍ឯក **ម៉ាត់ ជាឡា** អត្តលេខ ០០០៤៣៩

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក

១-ឧត្តមសេនីយ៍ទោ **គង់ ម៉ុនថន** អត្តលេខ ០០០១៣១

២-ឧត្តមសេនីយ៍ទោ **យឹម ម៉ុនធឿន** អត្តលេខ ០០០៩៤៨

មាត្រា២ : តែងតាំងមុខតំណែង នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ៖

ក-តែងតាំងមុខតំណែងជា រដ្ឋលេខាធិការ ក្រសួងការពារជាតិ ចំនួន ០៦ រូប

១-នាយឧត្តមសេនីយ៍ **ហម គិន** អត្តលេខ ០០០០៧០

២-នាយឧត្តមសេនីយ៍ **មាស ថង** អត្តលេខ ០០០០៩៤

៣-នាយឧត្តមសេនីយ៍ **តេង ឈួន** អត្តលេខ ០០០៣១៧

៤-នាយឧត្តមសេនីយ៍ **ជា សារ៉ែន** អត្តលេខ ០០០០៩០

៥-នាយឧត្តមសេនីយ៍ **ម៉ៅ ឆែន** អត្តលេខ ០០០១១៧

៦-នាយឧត្តមសេនីយ៍ **ម៉ាត់ ជាឡា** អត្តលេខ ០០០៤៣៩

ខ-តែងតាំងមុខតំណែងជា អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ ចំនួន ០២ រូប

១-ឧត្តមសេនីយ៍ឯក **គង់ ម៉ុនថន** អត្តលេខ ០០០១៣១

២-ឧត្តមសេនីយ៍ឯក **យឹម ម៉ុនធឿន** អត្តលេខ ០០០៩៤៨

មាត្រា៣: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០២០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

នស.រកត.១០២០.១០៩៤

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសល្យបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២០/ ១០៧៧

ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅនៃ
ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលសរសេរជាអក្សរកាត់ថា **ក.ជ.វ.ប.ន.** ដើម្បីជំរុញកិច្ចអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានការរីកចម្រើន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ជំពូកទី២
សមាសភាពរបស់ គ.ជ.វ.ប.ន.

មាត្រា២ .-

គ.ជ.វ.ប.ន. មានសមាសភាពដូចខាងក្រោម៖

- នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា	ប្រធានកិត្តិយស
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	ប្រធាន
- រដ្ឋមន្ត្រីក្រសួងផែនការ	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	អនុប្រធាន
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប	អនុប្រធានអចិន្ត្រៃយ៍
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប	សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល១រូប	សមាជិក
- អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា១រូប	សមាជិក
- អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ១រូប	សមាជិក
- តំណាងស្ថាប័នសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មួយចំនួន	សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា១រូប	សមាជិក
- អគ្គនាយកនៃវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងនៃ **គ.ជ.វ.ប.ន.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ជំពូកទី៣
តួនាទីនិងភារកិច្ចរបស់ គ.ជ.វ.ប.ន.

មាត្រា៣ .-

គ.ជ.វ.ប.ន. មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលលើការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ សម្រេច និងជំរុញអនុវត្តន៍គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- សម្របសម្រួលដឹកនាំការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងក្របខណ្ឌអន្តរក្រសួង ស្ថាប័ន
- កំណត់តម្រូវការអាទិភាពនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលស្នើឡើងដោយក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ និងអង្គភាពឯកជនដែលពាក់ព័ន្ធ
- ពិនិត្យនិងសម្រេចលើសំណើដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលរៀបចំដោយលេខាធិការដ្ឋាន **គ.ជ.វ.ប.ន.**
- កៀរគរជំនួយនិងការគាំទ្រធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ដែលជាតម្រូវការនៃស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ពិនិត្យនិងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលើការយល់ដឹងនិងចែករំលែកផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ពិនិត្យនិងសម្រេចលើការវាយតម្លៃផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ជំរុញនិងលើកទឹកចិត្ត ការចូលរួម ការលើកស្ទួយក្នុងកិច្ចអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ពីគ្រប់មជ្ឈដ្ឋាន
- កំណត់គោលការណ៍អភិវឌ្ឍធនធានមនុស្ស ដើម្បីបម្រើតម្រូវការនិងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងគម្រោងកម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ហើយធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

ជំពូកទី៤
ការប្រព្រឹត្តទៅរបស់ គ.ជ.វ.ប.ន.

មាត្រា៤ .-

គ.ជ.វ.ប.ន. ត្រូវធ្វើការប្រជុំយ៉ាងតិច២(ពីរ)ដងក្នុង១(មួយ)ឆ្នាំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ប្រធាន **គ.ជ.វ.ប.ន.** អាចកោះប្រជុំជាវិសាមញ្ញបាន។

នៅពេលដែលប្រធាន **គ.ជ.វ.ប.ន.** អវត្តមានឬមានករណីចាំបាច់ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានណាមួយដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

របៀបរបបការងារនិងកិច្ចដំណើរការប្រជុំរបស់ **គ.ជ.វ.ប.ន.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

មាត្រា៥ .-

ប្រធាន **គ.ជ.វ.ប.ន.** មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ឬឥស្សរជនដែលមានបទពិសោធន៍ សមត្ថភាព និងជំនាញវិជ្ជាជីវៈ ចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ **គ.ជ.វ.ប.ន.** តាមការចាំបាច់។

មាត្រា៦ .-

គ.ជ.វ.ប.ន. អាចមានទីប្រឹក្សានិងជំនួយការ ដែលជាអ្នកបច្ចេកទេសនិងជំនាញផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទាំងជាតិនិងអន្តរជាតិតាមការចាំបាច់។

មាត្រា៧ .-

គ.ជ.វ.ប.ន. មានគណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលប្រមូលផ្តុំដោយឥស្សរជន បញ្ញវន្ត និងអ្នកជំនាញផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គ្រប់មជ្ឈដ្ឋាន ដើម្បីជួយការងារឬផ្តល់យោបល់ជូន **គ.ជ.វ.ប.ន.**។

តួនាទីនិងភារកិច្ចរបស់គណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.វ.ប.ន.**។

មាត្រា៨ .-

គ.ជ.វ.ប.ន. មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាលេខាធិការដ្ឋាន។ អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាប្រធានលេខាធិការដ្ឋាន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន **គ.ជ.វ.ប.ន.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.វ.ប.ន.**។

លេខាធិការដ្ឋាន **គ.ជ.វ.ប.ន.** មានសិទ្ធិប្រើមន្ត្រីនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការបំពេញភារកិច្ច។

មាត្រា៩ .-

គ.ជ.វ.ប.ន. មានសិទ្ធិប្រើរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួនដែលកំណត់ដោយអនុក្រឹត្យ។

ជំពូកទី៥
ប្រភពធនធាន

មាត្រា១០ .-

ការចំណាយសម្រាប់ដំណើរការរបស់ **គ.ជ.វ.ប.ន.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

គ.ជ.វ.ប.ន. មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀតតាមបទដ្ឋានគតិយុត្តជាធរមានសម្រាប់ដំណើរការការងាររបស់ខ្លួន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា១១ .-

ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១៣៦ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១២ .-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ៥កើត ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២០

ក្នុងព្រះបរមនាមនិងតាមព្រះរាជបន្ទូលបង្គាប់
ប្រមុខរដ្ឋស្តីទី

នស/រកត/១០២០/១០៩៥

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

កិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២០/១០៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្តល់នីតិសម្បទាឡើងវិញឲ្យឈ្មោះ **ស៊ុន សុភ័ក្រ** ភេទ ប្រុស កើតថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៨៣ ដែលត្រូវបានហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំ តាមអំណាចសាលដីកាលេខៈ ៣៤០(ឆ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០២០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ចា.ត.ល. ២០១០.១០៩៦

ស.រ.

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២០/១០៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

